# សមាគមអក្សរសិល្បកម្ពុជា ស៊ុយអែដ

### សមាជនៅប្រទេស ស៊ុយអែដ ០២/០៦/២០០៩

អ្នកចូលរួមនៅក្នុងសមាជនេះមានចំនួន១១នាក់ គឺៈ លោក Stig Andersson, លោក Göran Borgelöv, លោក Jarl ammarberg, លោក Zabbar Neang, លោក Khon Channy, លោក Anders Jirås, អ្នកស្រី Marli Pettersson, អ្នកស្រី Lina Ekdahl, អ្នកស្រី Anita Neang, អ្នកស្រី Bianca Maria Barmen និង អ្នកនាង ពីរីន ជាភ្ញៀវកិត្តិយស។

### របៀបវារះ

១- ប្រធានសមាគម លោក Zabbar ស្វាគមន៍អ្នកចូលរួម និង ប្រកាសបើកអង្គប្រជុំ

២- អង្គប្រជុំទទួលស្គាល់របៀបវារះ

៣- អង្គប្រជុំជ្រើសយក អ្នកស្រី Marli ជាប្រធាននៃអង្គសមាជ

៤- អ្នកស្រី Anita បានជ្រើសជាលេខានៃអង្គសមាជ

៥- លោក Anders និង លោក Zabbar ត្រូវជ្រើសជាសាក្សីនៃកំណត់ហេតុរបស់អង្គប្រជុំ

៦- លោកស្រី Lina អាននូវរបាយការណ៍នៃការងារដែលសមាគមបានធ្វើក្នុងឆ្នាំ២០០៨។ អង្គប្រជុំទាំងមូលពុំមានការជំទាស់នូវការងារដែលបានធ្វើទេ។

អ្នកស្រី Lina មានការងឿងឆ្ងល់អំពីបញ្ហាដែល Anna Mattsson មិនសហការណ៍ជាមួយសមាគមកម្ពុជា-ស៊ុយអែដនៅកម្ពុជា ក្នុងការបកប្រែសៀវភៅ PIPPI ទៅជាភាសាខ្មែរ និង ទិវាសូត្រកំណាព្យរួមនៃប្រទេសអឺរុបខាងជើង និងប្រទេសកម្ពុជាដែលប្រារព្ធឡើងនៅក្នុងខែមិថុនា។ អ្នកស្រី Lina និងធ្វើការទាក់ទងជាមួយ Anna Mattsson ដើម្បីស្រាយបំភ្លឺនៃបញ្ហានេះ។

ចំណែកលោក Zabbar មានការងឿងឆ្ងល់ថា
តើហេតុអ្វីបានជាការធ្វើពាក្យសុំថវិការពីប្រទេស ស៊ុយអែដសំរាប់ចាយវាយលើបញ្ហាខាងលើនេះ គ្មានការចុះហត្ថាលេខាពីលោកផ្ទាល់ ។ លោក Zabbar ក៏ឆ្ងល់ទៀតដែរថា សូម្បីតែសៀវភៅ PIPPI ក៏គ្មានសរសេរអំពីសមាគមដែរ ។

លោក Channy មានបំណងចង់អោយសមាគមយករបាំប្រពៃណីខ្មែរ មកបង្ហាញជូនជនជាតិស៊ុយអែដឱ្យបានទស្សនា ។ លោក Anders យល់ថាគំនិតនេះល្អណាស់ហើយលោកនិងព្យាយាមទាក់ទងនាំយករបាំព្រះរាជទ្រព្យមកបង្ហាញនៅស៊ុយអ៊ែតនេះ ។

ចំណែកអ្នកនាង ពីវ៉ន ក៏បានចូលរួម ចែករំលែកយោបល់ដែរថា សមាគមគួរតែពិចារណានាំយកនូវក្មេងកំព្រាដែលបានហ្វឹកហាត់របាំនៅ តាមបណ្តាអង្គការនានា មកសំដែងនៅទីនេះដែរ ដើម្បីផ្តល់ឱកាសអោយអ្នកទាំងនោះបានបញ្ចេញ និង បង្ហាញនូវស្នាដៃរបស់ខ្លួន ។ លោក Anders និង លោក Channy ក៏ បានទទួលយល់ព្រមតាម សំណូមពររបស់អង្គប្រជុំ
ដើម្បីដោះស្រាយគំនិតថ្មីនេះ ។

៧- <u>របាយការប្រាក់ចំណូល និង ចំណាយ</u>

លោក Zabbar បានអាននូវរបាយការណ៍គណនេយ្យនៃចំណូល និង ចំណាយរបស់សមាគម ។ អង្គសមាជទាំងមូលគ្មានការជំទាស់ ។

៨- <u>របាយការណ៍អំពីអ្នកត្រួតពិនិត្យបញ្ជី</u>

អ្នកត្រួតពិនិត្យបញ្ជីគណនេយ្យ លោក Stig Andersson បានពិនិត្យបញ្ជី ហើយគ្មានឃើញបញ្ហាអ្វីខុសប្លែកពីធម្មតាទេ ។ លោកសំណូមពរឱ្យសមាជទទួលស្គាល់នូវបញ្ជីគណនៀ និងប្រគល់ការទុកចិត្តនេះដល់ក្រុមប្រឹក្សាភិបាលនៃសមាគមក្នុងអណត្តនេះ ។

៩- <u>ការផ្តល់សេចក្តីទុកចិត្ត</u>

សមាជបានយល់ព្រមផ្តល់សេចក្តីទុកចិត្តដល់ក្រុមប្រឹក្សាភិបាល ។

១០- <u>គំរោងថវិកា និង គំរោងការងារសរាប់ឆ្នាំ២០០៩</u>

បន្ទាប់ពីលោក Zabbar បានអាននូវគំរោងការងារ និង គំរោងថវិកាចប់ លោក Stig បានចោទសួរថា តើសមាគមមានថវិកាដែរទេសំរាប់ចែករង្វាន់ដល់ការប្រឡងប្រជែងស្នាដៃអ្នកនិពន្ធ? លោក Zabbar បានឆ្លើយថា យើងនឹងស្វែងរកប្រាក់នេះពីអ្នកឧបត្ថម្ភ។

១១- <u>ការជ្រើសរើសក្រុមប្រឹក្សាភិបាលឆ្នាំ២០០៩</u>

អង្គប្រជុំបានយល់ព្រមតាមការសំរេចចិត្តរបស់គណៈកម្មាធិការ ដោយសំរេចជ្រើសរើសបក្ខជនដែលមានរាយនាមដូចខាងក្រោមនេះ៰

ក- ប្រធាន លោក Zabbar Neang

ខ- សមាជិក អ្នកស្រី Marli Pettersson

អ្នកស្រី Anna Mellergård

អ្នកស្រី Kristin Bjarnedottir

អ្នកស្រី Anita Neang

គ- សមាជិករង អ្នកស្រី Lina Ekdahl

អ្នកស្រី Bianca Mari Barmen

អ្នកស្រី Biritta Larsson

ឃ- គណៈកម្មាការជ្រើសរើសបក្ខជន

លោក Göran Borgelöv

លោក Jarl Hammarberg

ង- គណៈកម្មាការត្រួតពិនិត្យគណនេយ្យ

លោក Stig Grundvall

លោក Khon Channy

១២- ផែនការក្រុមប្រឹក្សាភិបាល គ្មាន

១៣- កាស្នើរនៃសមាជិករបស់សមាគម គ្មាន

១៤- សមាជិកវិភាគទាន ១០០kr (12$)

១៥- សំនួរផ្សេងៗ

- សុំផ្ញើរតារាងឈ្មោះទាំងអស់ចែកអោយដល់សមាជិក
- សមាគមនឹងចូលរួមពិធីបុណ្យ Majorna ក្នុងខែកញ្ញានេះ
- សមាគមមានគំរោងប្រារព្ធពិធីចូលឆ្នាំខ្មែរនៅឆ្នាំ២០១០ ខាងមុខនេះ នៅ Göteborg

១៦- ប្រធានអង្គប្រជុំ អ្នកស្រី Marli Pettersson បានអរគុណដល់អ្នកចូលរួម និងប្រកាសបិទអង្គប្រជុំ។